ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១០ រ៨:ឧអធរ.សេដ្ឋ

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
**ជម្រាបមក**
**លោកប្រធានក្រុមហ៊ុន ខេមបូឌាន ខេ88 អិនដាស្ទ្រី ខ.ក**
( **ក្រុមហ៊ុន** CAMBODIAN K88 INDUSTRY CO.,LTD. )

**កម្មវត្ថុ** ៖ សេចក្តីជូនដំណឹងស្តីពីការប្រកាសលទ្ធផលក្រុមហ៊ុនដែលត្រូវបានជ្រើសរើស ដើម្បីបន្តអនុវត្តនីតិវិធីនៅក្នុងការផ្តល់អាជ្ញាបណ្ណស្វែងរុករករ៉ែនៅតំបន់ចំនួន ០១ទីតាំង ក្នុងខេត្តកំពង់ធំ ។

**យោង** ៖ សេចក្តីជូនដំណឹងលេខ ០២៤ រថ.ឧអធរ.សជណ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកប្រធានក្រុមហ៊ុន** ជ្រាបថា ក្រុមហ៊ុនរបស់លោកត្រូវបានជ្រើសរើសជាក្រុមហ៊ុនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសិទ្ធិអាទិភាព ដើម្បីបន្តអនុវត្តនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណស្វែងរុករកធនធានរ៉ែនៅតំបន់អូរចុស ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ និងឃុំសុចិត្រនិងឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ទំហំ ៩៣,៩៤ គីឡូម៉ែត្រក្រឡា ។

ទទួលបានសេចក្តីជូនដំណឹងនេះ លោកប្រធានក្រុមហ៊ុនត្រូវបិទផ្សាយនៅទីស្នាក់ការអាជ្ញាធរឃុំដែលតំបន់សម្បទាននេះស្ថិតនៅ និងអញ្ជើញមកទំនាក់ទំនងជាមួយនាយកដ្ឋានឧស្សាហកម្មអាជីវកម្មធនធានរ៉ែ នៅរៀងរាល់ម៉ោងធ្វើការដើម្បីពិនិត្យ និងពិភាក្សាអំពីនីតិវិធីដែលត្រូវអនុវត្តបន្តក្នុងរយៈពេលយ៉ាងយូរ **១៥(ដប់ប្រាំ)ថ្ងៃ** ចាប់ពីកាលបរិច្ឆេទនៃលិខិតនេះ ។

ផុតរយៈពេលកំណត់ខាងលើនេះ ក្នុងករណីក្រុមហ៊ុនរបស់លោកពុំបានចូលមកទំនាក់ទំនងបន្តនីតិវិធីស្របតាមការកំណត់ទេនោះ ក្រសួងរ៉ែ និងថាមពលចាត់ទុកថា ក្រុមហ៊ុនរបស់លោកបានបោះបង់ចោលសិទ្ធិអាទិភាពរបស់ខ្លួនក្នុងការទទួលបានអាជ្ញាបណ្ណស្វែងរុករករ៉ែនេះ។

អាស្រ័យហេតុនេះ សូម **លោកប្រធានក្រុមហ៊ុន** ជ្រាប និងយកចិត្តទុកដាក់អនុវត្តឱ្យបានទាន់ពេលវេលា។

សូម លោកប្រធានក្រុមហ៊ុន ទទួលនូវការរាប់អានអំពីខ្ញុំ។

ស៊ុយ សែម

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom PenhTel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh